00223330

A190/II 17

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១២)

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន័យ ថុល |
| | ចៅក្រម Katinka LAHUIS |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ១០ កញ្ញា ២០០៨ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 09 / 2008
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

សាធារណៈ:

## សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡៅ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យ៉ុង ផានិត

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

00223331



A190/II/2

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) បានកត់សម្គាល់ឃើញមាន “បណ្ដឹងឧទ្ធរណ៍របស់លោក **អៀង សារី** (“ជនត្រូវចោទ”) ដែលប្ដឹងចំពោះដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ស្ដីពីសិទ្ធិ និងកាតព្វកិច្ចបកប្រែរបស់ភាគី ដែលបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ (“បណ្ដឹងឧទ្ធរណ៍”) ។

២. អនុលោមតាមវិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវកំណត់ថ្ងៃសវនាការ បន្ទាប់ពីទទួលបានបណ្ដឹឧទ្ធរណ៍ ឬពាក្យសុំ ។[1]

៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្ដីសន្និដ្ឋានថា “ដោយសារលក្ខណៈនៃបណ្ដឹងឧទ្ធរណ៍នេះ សវនាការដេញដោលមិនចាំបាច់រៀបចំឡើយ ហើយបណ្ដឹងឧទ្ធរណ៍នេះ គួរយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍តែម្ដង។”[2]

៤. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ នៅក្នុងសេចក្ដីសន្និដ្ឋានតបចំពោះសារណាបណ្ដឹងឧទ្ធរណ៍របស់លោក **អៀង សារី** ស្ដីពីសិទ្ធិ និងកាតព្វកិច្ចបកប្រែរបស់ភាគី (“សេចក្ដីសន្និដ្ឋានតប”) សហព្រះរាជអាជ្ញាសន្និដ្ឋានដូចគ្នាដែរថា សវនាការដេញដោលមិនចាំបាច់រៀបចំឡើយ។[3]

៥. បន្ទាប់ពីធ្វើការពិចារណាការយល់ឃើញរបស់ភាគីដែលបានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ពួកគេរួចមក អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះអាចយកមកធ្វើការសម្រេច ដោយផ្អែកលើតែសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីបាន។

៦. អនុលោមតាមមាត្រា ៨(៤) នៃសេចក្ដីណែនាំស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក សំណើឆ្លើយតបចំពោះសារណាតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់។[4]

---

[1] វិធានផ្ទៃក្នុងនៃអ.វ.ត.ក (វិសោធនកម្មលើកទី១) ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

[2] បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះដីកាបង្គាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីពី សិទ្ធិនិងកាតព្វកិច្ចបកប្រែរបស់ភាគី ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ A190/II/1 វាក្យខណ្ឌទី ៦។

[3] សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះសារណាបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ស្ដីពីសិទ្ធិនិងកាតព្វកិច្ចបកប្រែរបស់ភាគី ចុះថ្ងៃទី១៥ ខែសីហា A190/II/៥ វាក្យខណ្ឌទី ៤។

[4] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច និងបង្គាប់:**

(១) ធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

(២) ជនត្រូវចោទអាចដាក់សារណាតប ចំពោះសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល**ប្រាំពីរ(៧)ថ្ងៃ** គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE ECCC

**ប្រាក់ គឹមសាន**